# គម្រោង
# ដាំត្រកួនសរីរាង្គ
# Organic Water Convolvulus Cultivation

រៀបចំដោយ
**គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ**
**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (អេ.អ.ឌី.ប៊ី)**
ខែតុលា ឆ្នាំ២០២២

# មាតិកា

I-**ស្ថានភាពទូទៅ** ....... ១
II-**បច្ចេកទេសដាំដុះ** ....... ១
១-រយៈពេលដាំដុះ ....... ១
២-រដូវកាលដាំដុះ ....... ១
៣-ការជ្រើសរើសពូជ ....... ១
៤-ការរៀបចំដី ....... ២
៥-វិធីដាំ ....... ៣
៦-ការស្រោចស្រព ....... ៣
៧-ការសម្អាតស្មៅ ....... ៣
៨-កត្តាចង្រៃ ....... ៤
៩-វិធីប្រើប្រាស់ថ្នាំកម្ចាត់សត្វល្អិត និងជំងឺផ្សិត ....... ៤
១០-ការដាក់ជីបំប៉ន ....... ៤
១១-ការប្រមូលផល ....... ៤
១២-ទិន្នផល ....... ៤
១៣-បញ្ហាប្រឈម ....... ៤
១៤-កត្តាជោគជ័យ ....... ៤
III-**ថ្លៃដើមផលិតកម្ម និងការវិភាគសេដ្ឋកិច្ច** ....... ៥
-ការវិភាគសេដ្ឋកិច្ចលើការដាំដុះក្នុង១វគ្គ ....... ៥
-តារាងចំណូល-ចំណាយលម្អិត ....... ៦
IV-**លទ្ធភាពចំណេញដោយផ្អែកលើនិន្នាការតម្លៃ** ....... ៦
V-**ខ្សែច្រវាក់តម្លៃ** ....... ៧
VI-**ការដាំដុះលក្ខណៈទិលដុំ** ....... ៧
VII- **ហានិភ័យ** ....... ៨
VIII-**សេចក្តីសន្និដ្ឋាន** ....... ៨

## I-ស្ថានភាពទូទៅ

ត្រកួន គឺជាប្រភេទបន្លែបៃតងដែលប្រជាជនកម្ពុជាភាគច្រើននិយមបរិភោគ។ គ្រប់ចំណែករបស់ដើមត្រកួន ទាំងដើម និងស្លឹក អាចយកមកចម្អិនធ្វើជាម្ហូបអាហារទទួលទានបានច្រើនមុខ អាចបរិភោគត្រួយខ្ចីៗស្រស់ៗឆៅៗ ឬស្រុសធ្វើជាអន្លក់ ឆា ស្លម្ល។ ត្រកួនមានផ្ទុកសារធាតុដែក ប្រូតេអ៊ីន និងវីតាមីនជាច្រើនប្រភេទ។ ត្រកួនជាប្រភេទដំណាំដែលងាយស្រួលក្នុងការដាំដុះ ដោយសារដំណាំនេះអាចដុះលូតលាស់បានទាំងនៅលើដី និងនៅលើទឹក តែកសិករភាគច្រើនចូលចិត្តដាំត្រកួននៅលើដី ព្រោះងាយស្រួលក្នុងការប្រមូលផល។ បន្លែត្រកួនមានច្រើនពូជ តែសម្រាប់នៅប្រទេសយើង គេនិយមដាំ “ត្រកួនចិន”។ ត្រកួនចិនមានលក្ខណៈជាដើមត្រង់ៗ ពណ៌បៃតងខ្ចី មានផ្កាពណ៌ស កម្ពស់ប្រមាណជា៤០-៥០សង់ទីម៉ែត្រ។ អាចនិយាយបានថា ត្រកួនចិន គឺជាបន្លែចម្ការក្នុងផ្ទះដ៏ពេញនិយមដែលងាយស្រួលដាំ និងអាចបេះយកមកធ្វើជាអាហារបានពេញមួយឆ្នាំ។

## II-បច្ចេកទេសដាំដុះ

ផ្អែកលើបទពិសោធន៍ និងការអនុវត្តជាក់ស្តែងរយៈពេល១០ឆ្នាំមកហើយ ព្រមទាំងភាពជោគជ័យលើការដាំបន្លែស្លឹកលើទីវាលរបស់បណ្តុំកសិករនៅស្រុកពាមជរ ខេត្តព្រៃវែង÷

**១-រយៈពេលដាំដុះ** ÷ ចាប់ពីដាំរហូតដល់ប្រមូលផលមានរយៈពេលពី ១៨ ទៅ ២១ថ្ងៃ។

**២-រដូវកាលដាំដុះ** ÷ កសិករអាចដាំត្រកួនបានគ្រប់រដូវកាល ដោយមិនប្រកាន់រដូវឡើយ។

**៣-ការជ្រើសរើសពូជ** ÷ ពូជត្រកួនដែលកសិករនិយមដាំដុះរួមមាន÷

ពូជ LIAO 9

ពូជ MSG

ពូជ Agri Bamboo 66

ពូជត្រកួនស្លឹកតែ

- ពូជ LIAO 9 មកពីប្រទេសវៀតណាម ផលិតដោយក្រុមហ៊ុន East west seed
- ពូជ អ៊ឹម អេស ជី មកពីប្រទេសថៃ ផលិតដោយក្រុមហ៊ុន Maly San Group Co.,Ltd
- ពូជ Agri Bamboo 66 មកពីប្រទេសវៀតណាម ផលិតដោយក្រុមហ៊ុន Agriscience
- ពូជ ត្រកួនស្លឹកតែ មកពីប្រទេសវៀតណាមផលិតដោយក្រុមហ៊ុន មិត្តកសិករ

## ៤-ការរៀបចំដី÷

ការភ្ជួររាស់ដីត្រូវធ្វើយ៉ាងហោចណាស់ ៣ ទៅ ៤លើក ដែលធ្វើឱ្យដីធូរ ងាយជ្រាបទឹកបានល្អ និងធ្វើឱ្យស្មៅងាប់។ កសិករគួរភ្ជួរដីជម្រៅពី ២៥-៣០ ស.ម រាស់បំបែកដីឱ្យល្អិត បាចជីលាមកសត្វផេះ ឬជីកំប៉ុស ហើយហាលដីទុកចោលរយៈពេល៧-១០ថ្ងៃ។

-រងូវស្បាត្រូវលើករងដែលមានទទឹង ១០០-១២០ស.ម ចន្លោះពីរងមួយទៅរងមួយពី ៣០-៥០ស.ម និងមានកម្ពស់ពី២០-២៥ ស.ម។

-រងូវប្រាំង ត្រូវទាញដីពីក្នុងរងធ្វើជាទំនប់តូចនៅជុំវិញរងដើម្បីឱ្យងាយដក់ទឹកក្នុងរង ដោយមានទទឹង ១០០-១២០ ស.ម និងត្រូវមានជម្រៅ ១០ ស.ម សម្រាប់ដីល្បាយខ្សាច់។

-ម្យ៉ាងទៀត កសិករអាចភ្ជួរ និងរាស់ដីឱ្យរាបស្មើល្អ រួចបែងចែកជាកូនស្រែ ហើយព្រោះគ្រាប់ត្រកួនលើដីនោះ ដោយពុំចាំបាច់លើករង។

**៥-វិធីដាំ ÷** ដាំគ្រាប់ផ្ទាល់នៅលើដីដែលបានរៀបចំរួចរាល់

-សម្រាប់ការលើកជារង យើងអាចព្រោះគ្រាប់ជាជួរទទឹងរង ឬតាមបណ្តោយរងក៏បាន ដោយទុកចន្លោះពីជួរមួយទៅមួយទៀត ២០សង់ទីម៉ែត្រ ប្រើគ្រាប់ពូជ ៣០ក្រាមក្នុងមួយម៉ែត្រការ៉េ បន្ទាប់មកទៀតយកចំបើងគ្របពីលើដើម្បីរក្សាសំណើមរបស់ដី ឱ្យត្រកួនលូតលាស់បានល្អ។

-កសិករអាចបែងចែកកូនស្រែទៅតាមម៉ែត្រការ៉េ បន្ទាប់មកយើងយកគ្រាប់ត្រកួនមកព្រោះ ដោយកំណត់ ៣០ក្រាមក្នុងមួយម៉ែត្រការ៉េ បន្ទាប់មកទៀតយកចំបើងគ្របពីលើដើម្បីរក្សាសំណើមរបស់ដីដើម្បីឱ្យត្រកួនលូតលាស់បានល្អ។

**៦-ការស្រោចស្រព ÷** ធ្វើឡើងទៅតាមវគ្គនៃការលូតលាស់នៃដំណាំត្រកួន

ត្រកួនជាបន្លែដែលធន់នឹងទឹក ដូចនេះយើងត្រូវស្រោចទឹកពីរដងក្នុងមួយថ្ងៃ ដើម្បីធានាថាដីដែលដាំត្រកួនមិនស្ងួត ឬត្រកួនស្រពោន។ កសិករអាចប្រើប្រាស់ប្រព័ន្ធសាចទឹក (Sprinkler) ទុយោសាច (rain tube) ឬទុយោស្រោចដោយដៃ។

**៧-ការសម្អាតស្មៅ÷** ដោយអាយុកាលរបស់ត្រកួនមានរយៈពេលខ្លី ១៨ ទៅ ២១ថ្ងៃ មិនតម្រូវឱ្យកសិករចាំបាច់ត្រូវសម្អាតស្មៅឡើយ។

**៨-កត្តាចង្រៃដែលកើតមានលើដំណាំត្រកួន÷**

សត្វទៀកគួ

ជំងឺផ្សិតលើដំណាំត្រកួន

**៩-វិធីប្រើប្រាស់ថ្នាំកម្ចាត់សត្វល្អិត និងជំងឺផ្សិត** ÷ គួរជ្រើសរើសថ្នាំជីវសាស្ត្រប្រភេទ beauveria bassiana សម្រាប់ប្រើលើសត្វទៀកគួរ និង Trichoderma សម្រាប់ប្រើប្រាស់លើជំងឺផ្សិត។

**១០-ការដាក់ជីបំប៉ន** ÷ តាមការបញ្ជាក់របស់កសិករដាំបន្លែសរីរាង្គ បានប្រើប្រាស់ជីលាមកមាន់នៅពេលរៀបចំដីតែមួយលើកប៉ុណ្ណោះ ដោយដាក់០.៥គីឡូក្រាមក្នុងម៉ែត្រការ៉េ។

**១១-ការប្រមូលផល**÷ ពីពេលដាំដុះដល់ពេលប្រមូលផលប្រើរយៈពេល ១៨ ទៅ ២១ថ្ងៃ

**១២-ទិន្នផល** ÷ ទិន្នផលអាស្រ័យទៅលើប្រភេទពូជ រដូវកាលដាំដុះ និងតំបន់ ដោយជាមធ្យមទទួលបានទិន្នផលពី ២៥-៣០ តោនក្នុង១ហិកតា។

**១៣-បញ្ហាប្រឈម** ÷ សត្វល្អិត ជំងឺផ្សិត កំដៅខ្លាំងធ្វើឱ្យត្រកួនមិនអាចលូតលាស់បានល្អ។

**១៤-កត្តាជោគជ័យ** ÷ ជាដំណាំដែលមានរយៈពេលខ្លី ងាយស្រួលក្នុងការដាំដុះ មិនសូវមានកត្តាចង្រៃបំផ្លាញដំណាំ។

## III-ថ្លៃដើមផលិតកម្ម និងការវិភាគសេដ្ឋកិច្ច

សិក្សាលើបទពិសោធន៍ និងភាពជោគជ័យរបស់បណ្តុំកសិករដាំបន្លែនៅស្រុកពាមជរ ខេត្តព្រៃវែង ដែលអនុវត្តការដាំដុះបន្លែស្លឹករយៈពេល១០ឆ្នាំមកហើយ

-បច្ចេកទេស÷ អនុវត្តន៍តាមទម្លាប់ និងទទួលបានការណែនាំបន្ថែមពីក្រុមហ៊ុនទិញបន្លែសិរីរាង្គ

-រយៈពេលដាំដុះរហូតបានប្រមូលផល÷ ១៨ ថ្ងៃ

-រដូវកាលដាំដុះ÷ ដាំដុះបានគ្រប់រដូវ (ដាំបាន១០វគ្គ/ឆ្នាំ)

-ទីផ្សារ÷ក្រុមហ៊ុនប្រមូលទិញបន្លែសិរីរាង្គចុះប្រមូលទិញដល់ចំការ

-និន្នាការតម្លៃ÷ តម្លៃត្រកួនបោះដុំ ចាប់ពី ១,៧០០៛ ដល់ ១,៨០០៛/គ.ក

-ផ្ទៃដីដាំដុះ÷ ៤អា (៤០០ ម៉$^{២}$)

-ទិន្នផលទទួលបាន÷ ៨០០គ.កក្នុង៤០០ម៉$^{២}$ ឬ (២០តោន ក្នុងមួយហិកតា)

-តម្លៃជាមធ្យមឆ្នាំ២០២២÷ ត្រកួនលក់ទៅក្រុមហ៊ុនប្រមូលទិញបន្លែសិរីរាង្គក្នុងតម្លៃ ១ ៧០០៛/គ.ក

**-ដើមទុនសម្រាប់ការចាប់ផ្តើមដាំដំបូងលើផ្ទៃដីទំហំ៤អា÷**

| បរិយាយ | ចំនួនទឹកប្រាក់ (រៀល) |
|---|---|
| ចំណាយលើការដាំដុះ-ថែទាំ | 606,000 |
| ចំណាយលើការរៀបចំប្រព័ន្ធស្រោចស្រព | 800,000 |
| សម្ភារៈផ្សេងៗ | 870,000 |
| **សរុប** | 2,276,000 |

**-ការវិភាគសេដ្ឋកិច្ចលើការដាំដុះក្នុង១វគ្គ÷**

ការវិភាគសេដ្ឋកិច្ចលើការដាំដុះបន្លែត្រកួនក្នុង១វដ្ត លើផ្ទៃដី ៤០០ម៉$^{២}$ រយៈពេល ១៨ថ្ងៃ ក្រោយកាត់រំលស់លើការចំណាយថេរ÷

| ចំណូលសរុប (រៀល) | ចំណាយសរុប (រៀល) | ចំណេញសរុប (រៀល) |
|---|---|---|
| 1,360,000 | 642,666 | 717,333 |

-តារាងចំណូល-ចំណាយលម្អិត÷

| បរិយាយ | ឯកត្តា | ចំនួនឯកត្តា | តម្លៃក្នុង ១ឯកត្តា (រៀល) | ទឹកប្រាក់សរុប (រៀល) | ចំនួនសារំលោះ | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|
| **១-ចំណូលពីការលក់ត្រកួន** | គ.ក | 800 | 1,700 | 1,360,000 | | 1,360,000 |
| **២-ចំណាយសរុប = ចំណាយប្រែប្រួល + ចំណាយមិនប្រែប្រួល/ថេរ** | | | | | | 642,666.67 |
| **២.ក.ចំណាយប្រែប្រួល** | | | | | | 606,000 |
| ភ្ជួររាស់ | លើក | 2 | 20,000 | 40,000 | | 40,000 |
| ពូជត្រកួន | កញ្ចប់ | 12 | 13,000 | 156,000 | | 156,000 |
| ជីលាមកសត្វ (មាន់) | ការ៉ុង | 1 | 50,000 | 50,000 | | 50,000 |
| ថ្នាំពុលធម្មជាតិ | ដង | 1 | 100,000 | 100,000 | | 100,000 |
| ថ្លៃកម្មករដាំ និងថែទាំ | នាក់ | 2 | 25,000 | 50,000 | | 50,000 |
| ជួលកម្មករប្រមូលផល | នាក់ | 4 | 25,000 | 100,000 | | 100,000 |
| ប្រេងម៉ាស៊ូតបូមទឹក | លីត្រ | 20 | 5,500 | 110,000 | | 110,000 |
| **២.ខ.ចំណាយមិនប្រែប្រួល/ថេរ (រំលោះ ១០វដ្ត/ឆ្នាំ)** | | | | | | 36,667 |
| ម៉ាស៊ីនបូមទឹកឲសេស (ប្រើ៥ឆ្នាំ) | គ្រឿង | 1 | 400,000 | 400,000 | 50 | 8,000 |
| ប្រព័ន្ធទឹក (ប្រើបាន៣ឆ្នាំ) | ឈុត | 1 | 400,000 | 400,000 | 30 | 13,333 |
| ធុងបាញ់ថ្នាំ ២០លីត្រ (ប្រើ៣ឆ្នាំ) | ឈុត | 1 | 130,000 | 130,000 | 30 | 4,333 |
| អណ្តូងបុក (ប្រើ១០ឆ្នាំ) | ឈុត | 1 | 500,000 | 500,000 | 100 | 5,000 |
| ស្បៃពណ៌ខៀវ (ប្រើ៤ឆ្នាំ) | ដុំ | 4 | 60,000 | 240,000 | 40 | 6,000 |
| ៣-ចំណេញសរុប | | | | | | 717,333 |
| ថ្លៃដើម/គ.ក = ចំណាយសរុប/ទិន្នផល | | | | | | 803.33 |
| ចំណេញ/គ.ក = ចំណេញសរុប/ទិន្នផល | | | | | | 897 |

**IV-លទ្ធភាពចំណេញដោយផ្អែកលើនិន្នាការតម្លៃ ÷**

| ករណី | តម្លៃ (រៀល) | ទិន្នផល (គ.ក) | ចំណូល (រៀល) | ចំណាយ (រៀល) | ចំណេញ (រៀល) | ចំណេញធៀបចំណាយ % |
|---|---|---|---|---|---|---|
| ករណីទី១ | 1,700 | 800 | 1,360,000 | 642,667 | 717,333 | 112% |
| ករណីទី២ | 1,800 | 800 | 1,440,000 | 642,667 | 797,333 | 124% |

## V-ខ្សែច្រវាក់តម្លៃ

កសិករ → ក្រុមហ៊ុនប្រមូលទិញបន្លែសរីរាង្គ → អ្នកប្រើប្រាស់

-លក់ក្នុងតម្លៃ ១,៧០០៛/គ.ក
-ថ្លៃដើមផលិត ៨០៣៛/គ.ក
-ចំណេញ៨៩៧៛/គ.ក

-លក់ចេញក្នុងតម្លៃ ៩,៣២០៛/គ.ក (២៤/០៩/២០២២)
-ចំណាយលើការដឹកជញ្ជូន ៥០០៛/គ.ក វេចខ្ចប់៥០០៛/គ.ក ចំណាយបុគ្គលិក១០០០៛/គ.ក ជួលហាង១០០០៛/គ.ក ការធ្វើសំណាកគីមី៥០០៛/គ.ក និងការខូចខាតផ្សេងៗ ៥០០៛/គ.ក) សរុប ៤០០០៛/គ.ក
-ចំណេញ ៣៦២០៛/គ.ក

## VI-ការដាំដុះលក្ខណៈទិលជុំ

តម្រូវការផ្ទៃដីដាំដុះវិលជុំដើម្បីទទួលបានចំណូល ៦,០០០ដុល្លារ ឬ ២៤,០០០,០០០រៀលក្នុង១ថ្ងៃ

| ករណីដោយផ្អែកតាមតម្លៃលក់/គ.ក | **លទ្ធផលជាក់ស្តែងក្នុង១ហិកតា** | | | **ផែនការ** | | |
|---|---|---|---|---|---|---|
| | ទិន្នផលជាមធ្យម គ.ក/ហ.ត | តម្លៃ រៀល/គ.ក | ចំណូលពីការលក់សរុប | ចំណូលពីការលក់ 6000 $/ថ្ងៃ | តម្រូវការផ្ទៃដីដាំដុះ/វដ្ត ជាហិកតា | តម្រូវការផ្ទៃដីដាំដុះវិលជុំ ជាហិកតា |
| A | B | C | D=B*C | E | F=E/D | G=F*25[១] |
| **ករណីទី១** | 20,000 | 1,500 | 30,000,000 | 24,000,000 | 0.80 | 20.00 |
| **ករណីទី២** | 20,000 | 1,600 | 32,000,000 | 24,000,000 | 0.75 | 18.75 |
| **ករណីទី៣** | 20,000 | 1,700 | 34,000,000 | 24,000,000 | 0.71 | 17.65 |
| **ករណីទី៤** | 20,000 | 1,800 | 36,000,000 | 24,000,000 | 0.67 | 16.67 |
| **ករណីទី៥** | 20,000 | 1,900 | 38,000,000 | 24,000,000 | 0.63 | 15.79 |
| **ករណីទី៦** | 20,000 | 2,000 | 40,000,000 | 24,000,000 | 0.60 | 15.00 |

[១] វដ្តនៃការដាំដុះត្រកួន១៨ថ្ងៃ និងការរៀបចំដី ៧ថ្ងៃ ដូច្នេះក្នុងមួយវដ្តនៃដំណាំត្រកួនត្រូវការរយៈពេល២៥ថ្ងៃ។

VII- **ហានិភ័យ ÷** តាមរយៈនៃការចុះសិក្សាជាមួយកសិករដាំដំណាំត្រកួន នៅស្រុកពាមជរ ខេត្តព្រៃវែង មានហានិភ័យមួយចំនួនអាចកើតឡើងជាយថាហេតុលើដំណើរការដាំដុះ នាំឱ្យបង្កផលវិបាក និងផលប៉ះពាល់ដល់ផលិតកម្មរបស់កសិករ។ ហានិភ័យចម្បងៗរួមមានដូចខាងក្រោម÷

| ល.រ | ប្រភេទហានិភ័យ | ពិពណ៌នាហានិភ័យ | វិធានការ |
|---|---|---|---|
| ១ | **ហានិភ័យផលិតកម្ម** | រដូវខ្លះទិន្នផលទទួលបានទាបជាងការរំពឹងទុក និងគុណភាពមិនសមស្រប ដោយសារ÷ សត្វល្អិត (ទាកគូ រុយស) និងជំងឺផ្សិត ភ្លៀងធ្លាក់ច្រើន | -គួរពិនិត្យលើការព្យាករណ៍អាកាសធាតុ និងធ្វើការជ្រើសរើសមុខដំណាំដែលសមស្របទៅនឹងអាកាសធាតុ ពូជធន់<br>-គួរដាំដុះដំណាំច្រើនប្រភេទផ្សេងគ្នា ដើម្បីជួយយោងគ្នា<br>-ត្រូវមានការត្រួតពិនិត្យ និងប្រើប្រាស់វិធានការដើម្បីថែទាំដំណាំដូចជា ជីកចង្អូរបង្ហូរទឹកពេលភ្លៀងធ្លាក់ជោកជាំពេក កែលម្អប្រព័ន្ធស្រោចស្រព អនុវត្តការប្រើប្រាស់ថ្នាំ និងជីត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស<br>-ជ្រើសរើសទីតាំងដាំដុះ ពិសេសគេចចេញពីតំបន់ដែលងាយសាយភាយសត្វល្អិតចង្រៃ។<br>-គួរដាំដុះក្នុងផ្ទះសំណាញ់ និងរៀបចំផែនការផលិតបន្លែផ្សេងទៀតជាមួយកសិករដទៃ ដើម្បីចៀសវាងការផលិតបន្លែតែមួយមុខដូចគ្នា ធ្វើឱ្យបន្លែជន់ថោក |
| ២ | **ហានិភ័យទីផ្សារ** | ការធ្លាក់ចុះនៃការលក់ និងតម្លៃគឺដោយសារមានការកើនឡើងនៃអ្នកប្រកួតប្រជែង ឬដោយសារមិនបានបំពេញតាមស្តង់ដារទីផ្សារ ឬតម្រូវការរបស់អ្នកទិញ ការវេចខ្ចប់មិនមានលក្ខណៈល្អប្រសើរ | -រៀបចំផែនការទីផ្សារជាមួយនឹងការព្យាករណ៍បរិមាណលក់ជាក់ស្តែង និងកំណត់តម្លៃគោល<br>-បង្កើតឬចូលរួមជាសមាជិកសហគមន៍ដើម្បីលើកកម្ពស់តម្លៃនិងធានាទីផ្សារ<br>-ពង្រីកបណ្តាញទីផ្សារឱ្យបានច្រើន មិនពឹងផ្អែកលើទីផ្សារតែមួយ<br>-ធ្វើកិច្ចសន្យាជាមួយអ្នកទិញ និងកំណត់អំពីរដូវកាលដាំដុះ ការប្រមូលផល និងការលក់តាមរដូវ<br>-ផលិតឱ្យបានទាំងបរិមាណ និងគុណភាពបំពេញតាមតម្រូវការអ្នកទិញ<br>-ធ្វើការស្រាវជ្រាវព័ត៌មានទីផ្សារចាំបាច់ |

## VIII-**សេចក្ដីសន្និដ្ឋាន**

ត្រកួនគឺជាបន្លែអចិន្ត្រៃយ៍ដែលប្រជាកសិករនិយមដាំដុះព្រោះងាយថែទាំ មិនសូវចំណាយដើមទុនច្រើន និងសម្បូរទីផ្សារ។ ថ្វីត្បិតតែការដាំដុះត្រកួនងាយស្រួលក៏ពិតមែន ប៉ុន្តែទាមទារឱ្យកសិករមានបច្ចេកទេសត្រឹមត្រូវក្នុងការដាំដុះដើម្បីទទួលបានទិន្នផលខ្ពស់។ ជាក់ស្ដែងកសិករដាំត្រកួននៅស្រុកពាមជរ ខេត្តព្រៃវែង តាមបែបសរីរាង្គ ទិន្នផលទទួលបានជាមធ្យម ២គ.ក/ម៉$^{២}$ឬ២០តោន/ហិកតា គឺល្អបង្គួរធៀបទៅនឹងទិន្នផលដែលអនុវត្តតាមគោលការណ៍បច្ចេកទេសនិងប្រើជីគីមី ២.៥-៣គ.ក/ម៉$^{២}$ ឬ ២៥-៣០តោន/ហិកតា។ ដើម្បីបង្កើនផលិតកម្មឱ្យកាន់តែខ្ពស់ កសិករគួរតែសិក្សាបន្ថែមអំពីការផលិតជីកំប៉ុស្តិ៍ ជីបំប៉ន និងថ្នាំពុលបែបធម្មជាតិសម្រាប់ប្រើប្រាស់ក្នុងដំណើរការដាំដុះ និងសិក្សាស្វែងរកពូជត្រកួនដែលផ្ដល់ទិន្នផលខ្ពស់ផងដែរ។

ត្រកួនមិនសូវខ្វះទីផ្សារនោះទេ ព្រោះមានឈ្មួញមកទទួលទិញដល់ចម្ការ។ ជាក់ស្ដែងសម្រាប់កសិករដាំត្រកួនសរីរាង្គនៅស្រុកពាមជរ មានក្រុមហ៊ុនប្រមូលទិញបន្លែសរីរាង្គចុះប្រមូលទិញដល់ចម្ការក្នុងតម្លៃ១,៧០០រៀល/គ.ក ដែលថ្លៃដើមផលិតត្រឹមតែ ៨០៣រៀល/គ.ក ដូចនេះកសិករអាចចំណេញ ៨៩៧រៀល/គ.ក។

បច្ចេកទេស ធាតុចូលក្នុងដំណើរការផលិតកម្ម ទីផ្សារ ទុនវិនិយោគ គួរត្រូវបានកំណត់ និងត្រៀមរួចរាល់មុនអាជីវកម្មត្រូវបានចាប់ផ្ដើម។ សិក្សាស្វែងយល់អំពីតម្រូវការទីផ្សារត្រូវអនុវត្តន៍ជាប្រចាំពីព្រោះចរន្តទីផ្សារតែងមានការផ្លាស់ប្ដូរទៅតាមបរិបទទីផ្សារប្រកួតប្រជែង៕

**ប្រភពនៃការសិក្សាស្រាវជ្រាវ៖**

-កសិករដាំដុះត្រកួនសរីរាង្គ ស្ថិតនៅឃុំកោះចេក ស្រុកពាមជរ ខេត្តព្រៃវែង

-ឯកសារបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ